## កិច្ចប្រជុំស្ដីពី
## ការពិនិត្យស្ថានភាពនៃការអនុវត្តការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧

# បទបង្ហាញស្ដីពី
# ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

ដោយៈ លោក ចាច់ សារី ទីប្រឹក្សាវិមជ្ឈការហិរញ្ញវត្ថុនៃលេខាធិការដ្ឋាន គ.ជ.អ.ប

# មាតិកា

១. លិខិតបទដ្ឋានគតិយុត្ត
២. សមត្ថកិច្ចគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក
៣. គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុក្រុងស្រុក
៤. ទស្សនទានទៅថ្ងៃអនាគត
៥. បញ្ហាប្រឈម

# ១. ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

**ក្របខណ្ឌច្បាប់៖**

- ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨)
- របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ
- លទ្ធកម្មសាធារណៈ

**អនុក្រឹត្យ៖**

- មូលនិធិក្រុង ស្រុក
- មូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

# ១. ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (ត)

**លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ៖**

- ✓ ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាក្រុង ស្រុក
- ✓ ការអនុវត្តនីតិវិធីប្រព័ន្ធទូទាត់ និងប្រព័ន្ធគណនេយ្យក្រុង ស្រុក
- ✓ វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ✓ គណៈកម្មាធិការ និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ✓ ការកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
- ✓ ការប្រគល់សិទ្ធិលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ✓ នីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ✓ ការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

# ២. សមត្ថកិច្ចគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក

**ក្រុមប្រឹក្សាក្រុង ស្រុក៖**

- ✓ ពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ
- ✓ ពិនិត្យ និងអនុម័តការកែសម្រួលថវិកាប្រចាំឆ្នាំ
- ✓ ពិនិត្យ និងអនុម័តរបាយការណ៍ហិរញ្ញវត្ថុ
- ✓ ពិនិត្យ និងអនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិក្រុង ស្រុក
- ✓ តាមដានត្រួតពិនិត្យការអនុវត្តហិរញ្ញវត្ថុ និងថវិការបស់អភិបាល

**អភិបាលក្រុង ស្រុក៖**

- ✓ រៀបចំគម្រោងថវិកាប្រចាំឆ្នាំ
- ✓ អនុវត្តថវិកាប្រចាំឆ្នាំ
- ✓ រាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តថវិកាប្រចាំឆ្នាំ

# ២. សមត្ថកិច្ចគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក

- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍អនុវត្តចំណូល ចំណាយប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- រាយការណ៍ជូនក្រសួង សហវ និងក្រសួងពាក់ព័ន្ធអំពីការអនុវត្ត និង ស្ថានភាពហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក
- គ្រប់គ្រងទ្រព្យសម្បត្តិដែលស្ថិតក្នុងដែនសមត្ថកិច្ចក្រុង ស្រុក
- ក្នុងនាមក្រុមប្រឹក្សា អភិបាលគឺជាអាណាប័កដើមខ្សែ ជាអ្នករៀបចំ និង អនុវត្តថវិកាក្រុង ស្រុក និងជាអ្នកបញ្ជាចំណូល សន្យាចំណាយ ជម្រះ បញ្ជី និងបញ្ជាចំណាយផ្ទេរតាមថវិកាអនុម័ត

# ៣. គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក

- សាច់ប្រាក់ត្រូវធានាដោយគណនេយ្យករ
- រតនាគារខេត្តបំពេញមុខងារជាគណនេយ្យករ
- ថវិកាប្រចាំឆ្នាំក្រុង ស្រុកផ្ដើមពីថ្ងៃទី០១ មករា បញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ
- ថវិកាក្រុង ស្រុកត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ
- ក្រុង ស្រុកគ្មានសិទ្ធិខ្ចីប្រាក់ពីគេ ឱ្យប្រាក់គេខ្ចី បោះផ្សាយសញ្ញាប័ណ្ណ...
- ចំពោះការទទួលហិរញ្ញប្បទានឥតសំណង រដ្ឋបាលក្រុង ស្រុក ត្រូវមានការឯកភាពជាមុនពីក្រសួង**មហាផ្ទៃ** និង ក្រសួង**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# ៣. គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក (ត)

## ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក

- ✓ ចំណាយប្រតិបត្តិការរដ្ឋបាល
- ✓ ចំណាយក្នុងការអនុវត្តមុខងារជាជម្រើស
- ✓ ចំណាយក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច
- ✓ ចំណាយក្នុងការអនុវត្តមុខងារដទៃទៀត

## ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុកនាពេលបច្ចុប្បន្ន

- ✓ មូលនិធិក្រុង ស្រុក
- ✓ ធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌ
- ✓ ចំណូលនៅមូលដ្ឋាន (មិនមែនសារពើពន្ធ)
- ✓ មូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ✓ ការចូលរួមធនធានពីដៃគូអភិវឌ្ឍន៍ និងពីប្រភពស្របច្បាប់ផ្សេងទៀត

# ៤. ទស្សនទាននៅអនាគត

- បង្កើនទំហំធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន (០,៥០%នៃចំណូលចរន្តថវិកាជាតិ) នៅឆ្នាំ២០១៩
- ធនធានថវិកាពីEUសម្រាប់សមាសភាពអភិវឌ្ឍ (២លានដុល្លារសម្រាប់ឆ្នាំ២០១៧ និង៤លានដុល្លារសម្រាប់២០១៨) ជាធនធានផ្តល់បន្ថែមលើមូលនិធិក្រុង ស្រុក
- ការរៀបចំឱ្យមានប្រភពចំណូលផ្ទាល់របស់ក្រុង ស្រុកតាមរយៈចំណូលចែករំលែកពីពន្ធរវាងរដ្ឋបាលខេត្តជាមួយរដ្ឋបាលក្រុង ស្រុក
- រដ្ឋបាលក្រុង ស្រុកនឹងទទួលបានការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិពីការផ្ទេរមុខងាររបស់ក្រសួងស្ថាប័ន (នេះជាចំណូលដ៏ធំមួយ)
- ចំនួនរដ្ឋបាលក្រុង ស្រុកច្រើនឡើងៗនឹងទទួលបានការផ្ទេរពីធនធានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

# ៥. បញ្ហាប្រឈម

- សមត្ថភាពរបស់មន្ត្រីជំនាញហិរញ្ញវត្ថុរបស់ក្រុង ស្រុកនៅមានកម្រិត
- នីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ និងថវិកាក្រុង ស្រុកមានភាពលំបាកសម្រាប់ការអនុវត្តនៅថ្នាក់ក្រុង ស្រុក
- កិច្ចដំណើរការរៀបចំគម្រោងថវិកាក្រុង ស្រុក ពុំទាន់បានបង្កលក្ខណៈឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ និងផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយ
- ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុក្រុង ស្រុកនៅមានកម្រិត (មិនចំគោលដៅ ឬអាទិភាព មិនទាន់មានតម្លាភាពពេញលេញក្នុងកិច្ចលទ្ធកម្ម...)
- ការរៀបចំសំណើផ្ទេរឥណទានប្រចាំត្រីមាសមានភាពយឺតយ៉ាវ

# អរគុណ!